K. 1419 [silacārik vatt girī stec gaṅ' K. 1419 secktī prae niṅ secktī atthādhippāy]

Kunthea Chhom

To cite this version:

Kunthea Chhom. K. 1419 [silacārik vatt girī stec gaṅ' K. 1419 secktī prae niṅ secktī atthādhippāy]. Kambuja Suriya, 2019, Special (Special), pp.35-54. hal-04097112

HAL Id: hal-04097112
https://hal.science/hal-04097112v1

Submitted on 22 Nov 2023

HAL is a multi-disciplinary open access archive for the deposit and dissemination of scientific research documents, whether they are published or not. The documents may come from teaching and research institutions in France or abroad, or from public or private research centers.

L'archive ouverte pluridisciplinaire HAL, est destinée au dépôt et à la diffusion de documents scientifiques de niveau recherche, publiés ou non, émanant des établissements d'enseignement et de recherche français ou étrangers, des laboratoires publics ou privés.

ចេញផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ
នៃក្រសួងធម្មការនិងសាសនា

Kambuja Soriya No. 4- 2019 កម្ពុជសុរិយា លេខ ៤ - ២០១៩

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយអក្សរសាស្ត្រសាសនា និង អក្សរសាស្ត្រទូទៅ



លោកស្រីសាស្ត្រាចារ្យបណ្ឌិត ពៅ សាវរស
( លេខពិសេស )

ឆ្នាំទី ៦៦ លេខ ៤ ខែ តុលា - វិច្ឆិកា - ធ្នូ
ព.ស. ២៥៦៣ គ.ស. ២០១៩

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយអក្សរសាស្ត្រសាសនា និងអក្សរសាស្ត្រទូទៅ

ចេញរាល់ត្រីមាស ពីពុទ្ធសាសនបណ្ឌិត្យ
នៃក្រសួងធម្មការ និងសាសនា

**លេខពិសេស**

ឧបត្ថម្ភការបោះពុម្ពដោយអង្គការ រីស្សូ កូសី-កៃ (RKK)
នៃប្រទេសជប៉ុន

# ចាត់ចែងបោះពុម្ពផ្សាយដោយពុទ្ធសាសនបណ្ឌិត្យ ៖

និពន្ធនាយក និងការផ្សាយ :  លោក **ស សុខនី**

## គណៈកម្មការនិពន្ធ

| | | |
|---|---|---|
| ១- ព្រះធម្មឃោសាចារ្យបណ្ឌិត | **ឃី** | **សុវណ្ណរតនា** |
| ២- លោកសាស្ត្រាចារ្យបណ្ឌិត | **វង់** | **សុធារ៉ា** |
| ៣- ឯកឧត្តមបណ្ឌិត | **ឆុយ** | **ចាន់ឆួន** |
| ៤- លោកស្រី | **ផាត់** | **ច័ន្ទមុនីរដ្ឋា** |
| ៥- លោក | **ឱម** | **វីរៈ** |
| ៦- លោក | **សំណាង** | **សំណាក់** |
| ៧- លោក | **ហ៊ីង** | **កោសល្យ** |

# មាតិកាអត្ថបទ លេខពិសេស


- កថាជូនលោកស្រីបណ្ឌិត ពៅ សាវរស .................................... ក
- កំណត់សម្គាល់ និងអក្សរកាត់ .................................................. គ
- សិលាចារឹកវត្តគិរីស្តេចគង់ K. 1419 ប្រវត្តិសិលាចារឹក និង ស្ថាននាម សុវណ្ណភូមិ (វង់ សុផារ៉ា) ........................................ ១
- សិលាចារឹកវត្តគិរីស្តេចគង់ K. 1419 អំណានអត្ថបទ និង លក្ខណៈតួអក្សរចារឹក (ហ៊ុន ឈុនតេង) .................................... ២៨
- សិលាចារឹកវត្តគិរីស្តេចគង់ K. 1419 សេចក្តីប្រែ និងសេចក្តី អត្ថាធិប្បាយ (ឆោម គន្ធា) ........................................................ ៣៥
- សិលាចារឹកភូមិដូង K. 1259 ( ឈុនតេង ) .............................. ៥៥
- សិលាចារឹក K. 1408 និង K. 1167 ( ជា សុជាតិ វ៉ាន់ វី, ហ៊ុន ឈុនតេង ) ......................................................... ៨២


III-<u>កំណត់ និងប្រវត្តិការណ៍</u>


- កម្រងរូបភាពស្តីអំពីសកម្មភាពការងារនៅពុទ្ធសាសនបណ្ឌិត្យ .............. ១១៩
- កម្រងរូបភាពស្តីអំពីការធ្វើបាឋកថាប្រចាំខែ នៅពុទ្ធសាសនបណ្ឌិត្យ ..... ១២១
- សេចក្តីជូនដំណឹងស្តីពីការជ្រើសរើសវាគ្មិនសម្រាប់ធ្វើបាឋកថាប្រចាំខែ.....១២២

## **កំណែ** / **Corrigenda**

ក្រុមអ្នកនិពន្ធអត្ថបទក្នុងទស្សនាវដ្ដីកម្ពុជសុរិយា លេខ៤ លេខពិសេស ឆ្នាំ២០១៩ សុំអភ័យទោសពីលោកអ្នកអាន ចំពោះរាល់កំហុសដែលកើតមានដោយអចេតនាក្នុងច្បាប់នេះ និងសុំកែតម្រូវដូចខាងក្រោម៖

| **ទំព័រនិងបន្ទាត់** **Page and line** | **ពាក្យខុស** **For** | **កំណែ** **Read** | **ទំព័រនិងបន្ទាត់** **Page and line** | **ពាក្យខុស** **For** | **កំណែ** **Read** |
|---|---|---|---|---|---|
| មាតិកា ប.១០ | (ឈុនតេង) | (ហ៊ុន ឈុនតេង) | ទំ.១២ ប.៤ | ជុំរុញ | ជំរុញ |
| មាតិកា ប.១៣ | III-កំណត់ | កំណត់ | ទំ.១៣ ប.១ | ប៉ូជនីយេសក៍ | បូជនីយេសក៍ |
| ទំ.ខ ប.៥ | ហ្ស៊ែក សឺដេស | ហ្ស៊ែក សេដែស | ទំ.១៧ ប.៣ | ជំន្ទះ | ជម្ទះ |
| ទំ.ខ ប.៦ | ហ្វីល្លីយ៉ហ្វាត់ | ហ្វីល្លីយ៉ូហ្វាត់ | ទំ.១៧ ប.២០ | អាមេរិច | អាម៉េរិក |
| ទំ.ខ ប.២០ | គេហស្ថាន | គេហដ្ឋាន | ទំ.២៦ ប.៥ | អ៊ីនធើណេត | អ៊ីនធឺណិត |
| ទំ.១ ប.៦ | ស្រុកបសេដ្ឋ | ស្រុកបរសេដ្ឋ | ទំ.៣២ ប.១៣, ទំ.៣៣ ប.១៧, ទំ.៣៦ ប.១៣ | –ស្ឫម្ទែក– | –ឫម្ទែក– |
| ទំ.២ ប.១ | សរសរពេជ្រ | សសរពេជ្រ | ទំ.៣២ ប.១៤ | –ធ្មុតាជូ– | –ធ្វូតាជូ– |
| ទំ.២ ប.៧ | សារឡើងវិញ | សាឡើងវិញ | ទំ.៣៣ ប.១០, ទំ.៣៦ ប.៦ | យយោសិ | យយោគិ |
| ទំ.២ ប.១៨ | កណ្ឌៀត | កណ្ដៀត | ទំ.៣៣ ប.១៨, ទំ.៣៦ ប.១៤ | –ធ្មុតាជូគិ | –ធ្វូតាជូគិ |
| ទំ.៤ ប.៨ | គគ្រឹគគគ្រេង | គគ្រឹកគគ្រេង | ទំ.៣៥ ប.១២, ទំ.៣៥ ប.១៤ | ប្រតិមា | បដិមា |
| ទំ.៦ ប.២១ | សិតាទិរាត្រី | សិតាទិរាត្រិះ | ទំ.៣៥ ប.១៥ | មួយរោច | មួយកើត |
| ទំ.៧ ប.៥ | សមាស្តសាមន្ត | សមស្តសាមន្ត | ទំ.៤០ ប.៥ | ១រោច | ១កើត |
| ទំ.៧ ប.៤ ទំ.១០ ប.៧ | –សុវណ្ណភូមិឫស្ត | –សុវណ្ណភូមិឫទ្ធ | ទំ.៤០ ប.១០ | ក្រឹស្ណ | ក្រឹស្ណះ |
| ទំ.១០ ប.១៣ | ឫស្ត | ឫទ្ធ | ទំ.៤០ ប.១១ | ៧- សេចក្ដី– | ៤- សេចក្ដី– |
| ទំ.១២ ប.៣, ទំ.១៩ ប.១ | សមិទ្ធិផល | សមិទ្ធផល | ទំ.៤០ ប.១២ | ៧.១- សុវណ្ណភូមិ– | ៤.១- សុវណ្ណភូមិ– |

| | | | | | |
|---|---|---|---|---|---|
| ទំ.៤១ ប.៤និង ៥ | ភីតបឺ ស្ដីល្លីង | ភីតបឺ ស្ដីល្លិង | ទំ.៧៣ ប.២៣ | ឬទ្ធិចេស្ដា | ឫទ្ធិចេស្ដា |
| ទំ.៤២ ប.២៣, ទំ.៤២ ប.២៤ | កល្យានី | កល្យាណី | ទំ.៧៥ ប.៩ | តាបងគ្រញូង | តាដំបងគ្រញូង |
| ទំ.៤៣ ប.១៩ | –រាជធិរាជស្រី ក្រឹតនគរ | –រាជាធិរាជស្រី កេតនេគរ | ទំ.៨៣ ប.១២ | កម្ពស់ : ១៥៤ ស.ម. | កម្ពស់ : ៤១ ស.ម. |
| ទំ.៤៣ ប.២០ | ព្រះរាជទេព បាលទេព | ព្រះរាជាទេព បាលទេព | ទំ.៨៣ ប.១២ | ទទឹង : ៥២,២០ស.ម. | ទទឹង : អតិ.២០ស.ម. អប្ប.១៩ស.ម. |
| ទំ.៤៥ ប.៩ | ឦស្វរសាសនិក | ឥស្វរសាសនិក | ទំ.៨៣ ប.១៣ | កម្រាស់ : ១២,៥០ស.ម. | កម្រាស់ : ៤ស.ម. |
| ទំ.៤៥ ប.១៣ | ៧.២- បទនានា | ៤.២- បទនានា | ទំ.១០០ ប.១៧ | ព្រះគុហា ហ្លួង | ព្រះគុហាហ្លួង |
| ទំ.៤៦ ប.១៧ | ៧.៣- កាល– | ៤.៣- កាល– | ទំ.១០០ ប.២៤ | បាននេះឡើយ | នេះបានឡើយ |
| ទំ.៤៩ ប.១៦ P.49, l.16 | –pr̥ṣthaika– | –pr̥ṣṭhaika– | ទំ.១០១ ប.៨ | គួហស្ថ | គូហស្ថ |
| ទំ.៦៨ ប.៨ | (K.205:18&37) | (K.205 : 18, K.206 : 37) | ទំ.១០១ ប.២៥ | ខាងនេះ | ខាងលើនេះ |
| ទំ.៦៩ ប.១៤ | នៅដែលតំបន់ នេះ ពេលស្ថិត | នៅពេលដែល តំបន់នេះស្ថិត | | | |

# សិលាចារឹកវត្តគិរីស្តេចគង់ K. 1419 សេចក្តីប្រែនិងសេចក្តីអត្ថាធិប្បាយ[1]

ដោយ **ឆោម គន្ធា**[2]

## ១- ខ្លឹមសារសង្ខេប

អត្ថបទចារឹកចារជាកំណាព្យភាសាសំស្ក្រឹតចំនួន២២បន្ទាត់ ត្រូវជា ១១ល្បះ។ តួអក្សរមានលក្ខណៈវិចិត្រ ចារលើផ្ទៃអត្ថបទចែកជាពីរប្រទ្បោះ ស្រដៀងនឹងការសរសេរកំណាព្យ(បទពាក្យ៧ ពាក្យ៨ ពាក្យ៩...)សម័យ ទំនើបនេះដែរ។ បីល្បះដំបូងជាបទនមស្ការចំពោះព្រះឥសូរ ព្រះស្រីសានវិស្ណុ (ព្រះឥសូរនិងព្រះវិស្ណុ) និងព្រះនារាយណ៍។ ល្បះទី៤ លើកសរសើរពីព្រះ បាទឦសានវម៌្មទី១ ជាកំពូលរាជាធិរាជ។ ល្បះទី៥ ដល់ល្បះទី៨ បង្ហាញពីតួ អង្គសំខាន់ជាអ្នកបម្រើ(ភ្ឫត្យ)របស់ព្រះមហាក្សត្រ មានឈ្មោះថា "វ្រៀងត្ត" និងកំណត់ត្រាអំពីការប្រតិស្ឋានប្រតិមាមួយចំនួននិងតង្វាយជាដីស្រែ គោ ក្របី។ ល្បះទី៩ ជាការដាក់បណ្តាសា។ ពីរល្បះចុងក្រោយ បង្ហាញពីកាល បរិច្ឆេទប្រតិស្ឋានប្រតិមាព្រះហរក្រឹស្ណៈ(ព្រះឥសូរនិងព្រះនារាយណ៍) ដោយ សាសនិកឈ្មោះវ្រៀងត្ត ពោលគឺនៅថ្ងៃទីមួយរោចខែចេត្រ(មីនា-មេសា) ឆ្នាំ ៥៥៥ នៃមហាសករាជ (៦៣៣ គ.ស.) ។

[1] ខ្ញុំសូមថ្លែងអំណរគុណចំពោះលោកសាស្ត្រាចារ្យនិងអ្នកស្រាវជ្រាវពីស្ថាប័នក្រៅស្រុកជាច្រើនដូចមាន រាយនាមនៅផ្នែកឧបសម្ព័ន្ធដែលបានចូលរួមក្នុងការបកប្រែពីភាសាសំស្ក្រឹតជាភាសាអង់គ្លេស។ ខ្ញុំក៏សូម អរគុណចំពោះលោកសាស្ត្រាចារ្យ មីស្ហែល ឫទ្ធី អង់តែល្ម លោក ហ៊ុន ឈុនតេង និងលោក ត្រេន្ត វ៉ក់ឃើ (Trent Wlaker) ដែលបានត្រួតពិនិត្យអត្ថបទនេះ។ រាល់កំហុសនិងកង្វះខាតនានា គឺជាទំនួលខុសត្រូវ របស់រូបខ្ញុំតែម្នាក់គត់។

[2] បណ្ឌិត **ឆោម គន្ធា** ជាអ្នកស្រាវជ្រាវនៃអាជ្ញាធរអប្សរា និងជាគ្រូបង្រៀនភាសាសំស្ក្រឹតនៅសាកលវិទ្យាល័យ ភូមិន្ទវិចិត្រសិល្បៈ។

## ២- អត្ថបទដើមជាអក្សរខ្មែរទំនើបកាត់ពាក្យរួច[3]

*ល្បះទី១ (បទ «ឧបជាតិ»)*

(ប១) ជយតិ អធីគស៊ សុរ-មៅលិ-កូដ-ចូឌាមណីនិ វិស្ផុរទ៊-ឧន្នយូខានិ

(ប២) វិជិត្យ តនិ-មូទ៌្ធសុ យស្យ បាទ-នខ-ប្រភាវិម៊ក្ខត-ចន្រ្ទ-កាន្តិះ //

*ល្បះទី២ (បទ «ឧបជាតិ»)*

(ប៣) គ្រីគាន-វ្លិម្ភ ជយតស៊ សុរេគៅ យយោស៊ គរីវាទ៌្-សមាគមេន

(ប៤) អារិរ៊-វ្ភូវាមរ-មាណវេប៊ុ វិភុត្វម៊ ឯកត្វម៊ អនេកតា ច //

*ល្បះទី៣ (បទ «ឥន្ទ្រវជ្រា»)*

(ប៥) វក្រេ្ត្រណ ធីគ៊ គ្រីរ៊ ឱរសា ច បទ្មាំ (ភូ)ប្បា[4]លិតាស្មត៊-បតិនា
-តិភាគ្យាតិ

(ប៦) ក្សិប្តា ហិ ទូរំ យទ៊ អហានិ តុ អឆន្យា យំ កីត៌្តិរ៊ ឱទ៊-ទិគ្ស វទេទ៊ ឥតីវ //

*ល្បះទី៤ (បទ«ឧបជាតិ»)*

(ប៧) សមុទ្របយ៌្យន្តសុវណ៌្ណភូមិស្ឫម្ភៃករាជេន្ទ្របរាក្រមគ្រីះ

(ប៨) សមស្តសាមន្តគិរោធ្ធតាជ្ញូគ៊ គ្រីគានវម៌្មា ជយតិ ក្សិតីគះ //

*ល្បះទី៥ (បទ «ឥន្ទ្រវជ្រា»)*

(ប៩) តស្យាបិ ភ្វត្យស៊ សមធត្ត សំជ្ញាំ វ្រៀ ឯត្ត ឥតិ អាត្មគុរុប្រទិត្តាំ

(ប១០) តតិប្ឫវ៌្ជេ ស្ថាបិតវតិ អនាទី គ្រីបុម្កវេគំ ប្រថមំ សុរាណាំ //

*ល្បះទី៦ (បទ«ឧបជាតិ»)*

(ប១១) គុរោស៊ ស្វភក្ត្យា ភគិនី មុរារេះ គ្រីគវ៌្វគោវិន្ទម៊ អតិម៌្មបតិ សះ

(ប១២) ស្វយម្តុទេវីភវកេគវានាំ តេនាបិ សំស្ថាបិត ឯកភោគះ (//)

*ល្បះទី៧ (បទ «ឥន្ទ្រវជ្រា»)*

(ប១៣) តេចាំ សុរាណាម៊ ឥហ ភ្វត្យសំខ្យា សំបិណ្ឌិតា ស្យាត៊ ត្រិគតី គវាញ៊ ច

---

[3] អត្ថបទជាអក្សរទំនើបនេះជាសម្រង់ពីអត្ថបទរបស់ ហ៊ុន ឈុនតេង នៅក្នុងសៀវភៅនេះ។

[4] តួអក្សរ ប នេះមានរូបរាងខុសពីតួ ប ធម្មតា។ តួនេះតាមពិតគឺជា វិសគ៌ (:) ហើយប្រែជា ប ដោយសារឥទ្ធិពល "សន្ធិ"។ ពេលវាឈរនៅមុខតួ ប ឬ ផ គេហៅវិសគ៌ប្រែភេទជា ប នេះថា "ឧបធ្មានីយ"។ នៅទីនេះ យើងប្រើអក្សរ ប ធម្មតា ដើម្បីកត់ត្រាតួ ឧបធ្មានីយ នេះសិន រង់ចាំដល់គេបង្កើតតួអក្សរថ្មីបាននៅក្នុងខ្មែរយូនីកូដ។

(ប១៤) សា ត្រឹគតី ក្បេត្រកមាហិចាណាំ ប្រត្យេកមិ អារាម ឥតិ
ត្រយាណាំ //

*ល្បះទី៨ (បទ «ឧបជាតិ»)*

(ប១៥) ឯតានិ គោកូធនបូរ្វ៌កានិ សវ៌្វាណិ ធម៌្មាត៌្ថមិ ឧបាជ្ជិតានិ
(ប១៦) បទេ កុលានាំ ស្វកុលែកទីបោ ព្រៀ ឯត្តនាមាទិត ទេវតាក្យះ //

*ល្បះទី៩ (បទ «ឧបជាតិ»)*

(ប១៧) យជ្វា ត្រយាណាមិ ឥហ ទេវតានាំ ទត្វា ធនំ យោ ហរតិ ស្ម
លោភាតិ
(ប១៨) សហ ប្រសូត្យា និរយេ និមជ្ជេទិ អាសំប្លវាតិ ស្លាវរជង្គមានាំ (//)

*ល្បះទី១០ (បទ «ឧបេន្ទ្រវជ្រា»)*

(ប១៩) សមា គកេន្ទ្រស្យ គរមេរុវាណៃរ វិនិគ៌្គតា ចៃត្រសិតាទិរាត្រិះ
(ប២០) យទាគ្នីនីគីតករោ នុយាត្រី តុលោទយោ មៃថុនភាគយុក្តះ (//)

*ល្បះទី១១ (បទ «ឧបជាតិ»)*

(ប២១) មីនាជវីនាឈបមាគ៌្គកុម្ភចាបក្រមស្លាគិ គុភលគ្នទាសិ តេ
(ប២២) ស្វៀយ៌្យាទយគិ គ្រីហរក្ឃម្ភមូត្តិមិ អតិម្និបតិ តាំ វិធិនេហ យជ្វា (//)

## ៣- សេចក្ដីប្រែ

### ល្បះទី១

សូមព្រះដ៏ជាកំពូលលើសគេ មានជោគមានជ័យ! រស្មីនៃព្រះបាទនខារបស់ព្រះអង្គនោះពេលបានឈ្នះអស់នូវបណ្ដាត្បូងមណីល្អឯកនានាលើមកុដនៃពួកទេវតា ដ៏ភ្លឺផ្លេកពណ្ណរាយ ហើយមិនកន្ថើយ ក៏បញ្ចេញរស្មីព្រះចន្ទ្រលើព្រះកេសនៃពួកទេវតានោះជំនួសវិញ ។

### ល្បះទី២

សូមព្រះទាំងពីរអង្គដ៏ជាស្ដេចនៃទេវតា ពោលគឺព្រះស្រីឦសាននិងព្រះស្រីវិស្ណុមានជោគមានជ័យ! ដោយគុណនៃការរួមបញ្ចូលគ្នានៃព្រះសរីរាង្គព្រះអង្គមួយចំហៀងរៀងព្រះអង្គ វត្តមានជានិច្ចនិរន្តរ៍ផង ឯកភាពផង ពហុ

ភាពផង បានកើតមានដល់ពួកមនុស្សនិងទេវតា។

**ល្បះទី៣**

ស្ដីពីព្រះរាជា ព្រះកិត្តិនាមរបស់ព្រះអង្គ ឧទានដូចនេះថា៖ «ព្រះរាជា ជាម្ចាស់ជីវិតនៃយើង ការពារនាងប្រាជ្ញាដោយសម្ដីហូរចេញពីព្រះឱស្ឋ ការពារនាងរូបសម្រស់ដោយព្រះឱរា ការពារនាងធរណីដោយព្រះបាទាទាំងទ្វេ។ ព្រះអង្គការពារធីតាទាំងបី ដោយសារតែពួកនាងមានភ័ព្វក្រៃលែង។ ចម្លែកអីតែអញខ្ញុំនេះ គ្មានភ័ព្វនឹងគេ ត្រូវព្រះអង្គប្រើឱ្យអណ្ដែតត្រសែតទៅទីឆ្ងាយៗ»។

**ល្បះទី៤**[5]

សូមព្រះបាទស្រីឦសានវម៌្ម មានជោគមានជ័យ! ពួកស្ដេចនគរចំណុះ នាំគ្នាទូលព្រះរាជបញ្ជាព្រះអង្គលើសិរសាតែរៀងខ្លួន។

ក- ព្រះអង្គប្រកបដោយសិរីសួស្ដីនិងវិភោគ ដូចព្រះឥន្ទ្រជាស្ដេចឯកនៅលើផ្ទៃនៃផែនដីមាស ទៅទល់នឹងសមុទ្រ។

ខ- ព្រះអង្គប្រកបដោយសិរីសួស្ដីនិងវិភោគ ដូចស្ដេចចក្រពត្តិ(ស្ដេចនៃស្ដេចទាំងឡាយ) ជាឯកនៅលើផ្ទៃនៃផែនដីមាស ទៅទល់នឹងសមុទ្រ។

គ- ព្រះអង្គប្រកបដោយសិរីសួស្ដីនិងវិភោគនៃស្ដេចចក្រពត្តិ ជាឯកនៅលើផ្ទៃដីមានព័ណ៌ស្រស់បំព្រង ទៅទល់នឹងសមុទ្រ។

---

[5] ដោយហេតុតែពាក្យសំស្ក្រឹតអាចមាននិយមន័យច្រើន និងកវីនិពន្ធភាសាសំស្ក្រឹតចូលចិត្តលេងសម្ដី បានជានៅក្នុងស្លោកនេះ អាចឱ្យបកស្រាយអត្ថន័យបាន៤យ៉ាង ដូចមានរាយក្នុងចំណុច «ក» ដល់ «ឃ»។ បន្ថែមពីលើចំណុចទាំង៤ដូចខាងលើ ល្បះនេះក៏អាចបកស្រាយន័យបាន២យ៉ាងទៀតដូចខាងក្រោម។ មូលហេតុយើងមិនដាក់បំណកស្រាយ២នេះជាមួយបំណកស្រាយទាំង៤ខាងលើ ពីព្រោះយើងចង់រក្សាសេចក្ដីប្រែជាខ្មែរដូចសេចក្ដីប្រែជាអង់គ្លេសនៅផ្នែកឧបសម្ព័ន្ធ។

ង- ព្រះអង្គប្រកបដោយសិរីសួស្ដីនិងវិភោគនៃស្ដេចចក្រពត្តិ ជាឯកនៅលើដែន(ដីឈ្មោះថា) សុវណ្ណភូមិ ទៅទល់នឹងសមុទ្រ។

ច- ព្រះអង្គប្រកបដោយសិរីសួស្ដីនិងវិភោគនៃស្ដេចចក្រពត្តិ ជាឯកនៅលើផ្ទៃ(ដីនៅក្នុងដែន) សុវណ្ណភូមិ ទៅទល់នឹងសមុទ្រ។

សូមអានសេចក្ដីអត្ថាធិប្បាយអំពីស្ថាននាមសុវណ្ណភូមិនៅក្នុងអត្ថបទរបស់លោកសាស្ត្រាចារ្យ វង់ សុធារ៉ា ក្នុងសៀវភៅនេះ។

ឃ- ព្រះអង្គប្រកបដោយសិរីសួស្តីនិងវិភាពនៃស្តេចចក្រពត្តិ ជាឯក នៅលើផ្ទៃដី(ឈ្មោះថា)សុវណ្ណ ទៅទល់នឹងសមុទ្រ។

**ល្បះទី៥**

វីរអាមាត្យម្នាក់របស់ព្រះរាជាបានទទួលឈ្មោះ «វ្រៀងត្ត[6]» ពីគ្រូរបស់លោកចង្អុលប្រាប់ ក្រោយពីបងប្រុសរបស់លោកបានតម្កល់ព្រះបដិមាស្រី បុស្ករេសៈ ដ៏ជាព្រះគ្មានទីចាប់ផ្ដើមនិងជាច្បងគេនៃទេពទាំងឡាយ។

**ល្បះទី៦**

លោកវ្រៀងត្ត បានតម្កល់ព្រះបដិមានៃព្រះភគិនី(បងឬប្អូនស្រី)នៃព្រះមុរារិ ព្រមទាំង ព្រះគវ៌(ឥសូរ) និងព្រះគោវិន្ទ(នារាយណ៍) ប្រកបដោយចិត្តភក្តីផ្ទាល់ខ្លួន ចំពោះព្រះគ្រូរបស់លោក។ បន្ថែមពីនោះ លោកក៏បានតម្កល់ថ្វាយអម្រស់អម្រួមតែមួយ(ឯកភោគ) ចំពោះព្រះនាងស្វយម្ភូទេពី[7] ព្រះភវ(ឥសូរ) និងព្រះកេគវ(ព្រះនារាយណ៍) ។

**ល្បះទី៧**

ចំនួនខ្ញុំបម្រើព្រះទាំងបីអង្គតម្កល់នៅទីនេះ បូកសរុបទៅត្រូវជាបីរយនាក់។ គោក៏មាន៣០០ដែរ។ ចំណែកឯក្របីនិងដីស្រែ មានសាមសិបមួយមុខៗ។ សួនអារាមមានសម្រាប់ព្រះគ្រប់ព្រះអង្គ។

**ល្បះទី៨**

លោកឈ្មោះវ្រៀងត្ត ដ៏ជាប្រទីបឯកបំភ្លឺវង្សត្រកូលរបស់ខ្លួន បានថ្វាយចំពោះពួកទេវតានៅទីនេះ ដែលជាកម្មសិទ្ធិរបស់វង្សត្រកូលដ៏ប្រសើរទាំងឡាយ នូវសព្វទ្រព្យធន មាន គោ ដី ជាដើមនេះ ដើម្បីទ្រទ្រង់ព្រះធម៌។

**ល្បះទី៩**

អ្នកជាម្ចាស់ទាន បានថ្វាយទ្រព្យធនចំពោះព្រះទាំងបីអង្គគង់នៅទីនេះ។

---

[6] វ្រៀងត្ត ទំនងជាឈ្មោះមួយមានន័យល្អ។ សូមអានសេចក្តីអត្ថាធិប្បាយអំពីឈ្មោះនេះក្នុងអត្ថបទរបស់លោកសាស្ត្រាចារ្យ មីស្ហែល ឫទ្ធី អង់តែល្ម នៅលេខក្រោយនៃកម្ពុជសុរិយា។

[7] សូមអានសេចក្តីអត្ថាធិប្បាយអំពីព្រះនាមនេះក្នុងសេចក្តីប្រែជាភាសាអង់គ្លេសនៃឧបសម្ព័ន្ធ។

នរជនណាហ៊ានយកទ្រព្យនេះដោយចិត្តលោភនិងចិត្តប៉ងបំផ្លាញ នរជននោះនឹងធ្លាក់ទៅនរកជាមួយកូនចៅខ្លួន ដរាបពួកសត្វនិករទាំងអស់ ទោះជាសត្វផ្លាស់ទីបានក្តី ផ្លាស់ទីមិនបានក្តី រលាយសាបសូន្យ[8]។

## ល្បះទី១០និង១១

ឆ្នាំមហាសករាជកន្លងទៅបាន៥៥៥ នៅថ្ងៃ១រោច ខែចេត្រ ចំពេលព្រះចន្ទ្រចរចំលើផ្កាយឫក្សឈ្មោះអស្វិនី រីឯផ្កាយឫក្សដែលជាប់មួយភាគនឹងមេថុនស្ថិតនៅល្វែងតុលៈ។ ចំណែកឯសប្តគ្រោះ មានព្រះអាទិត្យជាដើម ដ៏នាំមកនូវមង្គល គង់នៅរៀងគ្នាក្នុងល្វែងមីនៈ មេសៈ វីនា[9] មីនៈ មករា កុម្ភៈ និងធ្នូ[10]។ លោកម្ចាស់ទាន បានតម្កល់ព្រះបដិមារួមគ្នាមួយនោះនៃព្រះស្រី ព្រះហរ (ឥសូរ)និងព្រះក្រឹស្ណ(ព្រះនារាយណ៍) ទៅតាមក្បួនពិធីត្រឹមត្រូវ៕

## ៧- សេចក្តីអត្ថាធិប្បាយ

### ៧.១- សុវណ្ណភូមិ[11]

រដ្ឋនានានៅដែនដីអាស៊ីអាគ្នេយ៍សុទ្ធតែអះអាងថាជា «សុវណ្ណភូមិ» រៀងៗខ្លួន។ ចាប់ពីចុងខែធ្នូឆ្នាំ២០១៧មក មនុស្សម្នាបានដឹង ហើយនាំគ្នាចាប់អារម្មណ៍នឹងសិលាចារឹកនេះណាស់។ ចំណាប់អារម្មណ៍ខ្លាំងជាងគេនោះគឺពាក្យ «សុវណ្ណភូមិ» នៅក្នុងល្បះទី៤ដែលជាពាក្យផ្សំរវាងពាក្យ សុវណ្ណ (មាស) និង ភូមិ(ដែនដី)។ ពាក្យនេះប្រើក្នុងការសរសើរតម្កើងព្រះបាទណ្ឌៀសានវម្ម័ទី១ ជាស្តេចគ្រប់គ្រងលើដែនដីដែលគេព័ណ៌នាថាជា «សុវណ្ណភូមិ»។ ប្រជាជនខ្មែរនាំគ្នាយល់ថា ដែនដី «សុវណ្ណភូមិ» នោះ គឺជាឈ្មោះនគរ

---

[8] មានន័យថារហូតដល់ ភ្លើងឆេះកល្បរលាយលោកទាំងមូល។

[9] សូមអានសេចក្តីអត្ថាធិប្បាយអំពីពាក្យនេះនៅផ្នែកចុងនៃអត្ថបទនិងនៅក្នុងសេចក្តីប្រែជាភាសាអង់គ្លេសនៃឧបសម្ព័ន្ធ។

[10] ពោលគឺព្រះអាទិត្យគង់ចំល្វែងមីនៈ, ព្រះច័ន្ទ្រចំមេសៈ, ព្រះអង្គារចំវីនា, ព្រះពុធចំមីនៈ, ព្រះព្រហស្បត្តិ៍ចំមករៈ, ព្រះសុក្រចំកុម្ភៈ និងព្រះសៅរ៍ចំធ្នូ។

[11] នៅក្នុងសៀវភៅនេះ លោកសាស្ត្រាចារ្យ វង់ សុធារ៉ាពិភាក្សាអំពីពាក្យនេះ ដោយបង្ហាញយ៉ាងក្បោះក្បាយពីទិដ្ឋភាពប្រវត្តិសាស្ត្រ។ ចំណែកខ្ញុំសូមធ្វើសេចក្តីអត្ថាធិប្បាយខ្លីមួយដើម្បីចោទជាសំណួរនៅចុងបញ្ចប់អំពីហេតុមានពាក្យ «សុវណ្ណភូមិ» តែមួយក្នុងសិលាចារឹកកម្ពុជា។ មួយផ្នែកធំនៃសេចក្តីអត្ថាធិប្បាយនេះ គឺជាសម្រង់ចំនុចសំខាន់ៗពីអត្ថបទរបស់លោកសាស្ត្រាចារ្យ ភីតបឺ ស្គីល្លីង(ឆ្នាំ២០១៩)។

ខ្មែរមានព្រះបាទឮសានវម៌្មជាស្តេច។ តើការពិត «សុវណ្ណភូមិ» នៅទីណា?

ចំណោទនេះមិនមែនជារឿងថ្មីទេ។ មានអ្នកស្រាវជ្រាវអំពីអាស៊ីអាគ្នេយ៍ច្រើនរូបណាស់ បានកត់សម្គាល់និងបញ្ចេញមតិយោបល់ ទៅតាមចំណេះជំនាញរៀងខ្លួន។ កាលពីពាក់កណ្តាលឆ្នាំ២០១៩ លោកសាស្ត្រាចារ្យ ភីតឋឺ ស្គីល្លីង (Peter Skilling) បានបោះពុម្ពអត្ថបទមួយក្រោមចំណងជើងថា Many Lands of Gold (ដែនដីមាសនានា)។ អត្ថបទនេះអាចរាប់បានថាជាការវាយតម្លៃជារួមនូវគំនិតពីមុនៗអំពីដែនដីមាសមួយនេះ។ លោកស្នើថា សុវណ្ណភូមិ[12] មិនសំដៅដល់តំបន់ណាមួយនៃដែនអាស៊ីអាគ្នេយ៍ ពោលគឺមិនសំដៅដល់ប្រទេសណាមួយ រដ្ឋណាមួយ ឬទីនយោបាយណាមួយទេ។ អាចនិយាយម៉្យាងទៀតបានថាទ្វីបនានាឬនគរនានានៃអាស៊ីអាគ្នេយ៍ គឺស្ថិតនៅសុវណ្ណភូមិ ប៉ុន្តែគ្មានទ្វីបឬនគរណាមួយជាសុវណ្ណភូមិផ្តាច់មុខតែខ្លួនឯងឡើយ។

លោក ស្គីល្លិង បានលើកយកករណីចារឹកសុវណ្ណភូមិនេះជាករណីលើកលែងត្រង់សម្តីលោកពីមុនថាគ្មានចារឹកចាស់បុរាណជាភាសាបាលី ឬសំស្ក្រឹត ឬមនចាស់ ឬខ្មែរចាស់ណាមានពាក្យសុវណ្ណភូមិទេ។ លោកមិនអាចពិភាក្សាអំពីចារឹកនេះបានទេ រង់ចាំដល់មានការបោះពុម្ពណាមួយសិន។ ដើម្បីជាប្រយោជន៍ដល់សាធារណជនទូលំទូលាយ យើងខ្ញុំសូមភ្ជាប់ជូនឧបសម្ព័ន្ធជាភាសាអង់គ្លេសមួយនៅខាងក្រោយអត្ថបទនេះ។ នៅក្នុងនោះរួមមានសេចក្តីផ្តើម អំណាន និងសេចក្តីបកប្រែ។

លោក ស្គីល្លិង បានបញ្ជាក់ថា សុវណ្ណភូមិ អាចមានន័យចំថាជា ដែនដីសំបូរមាស ឬមានន័យធៀបថា ជាប្រភពនៃទ្រព្យ ពោលគឺដីសំបូរដីជាតិនិងរ៉ែជាដើម។ សុវណ្ណភូមិ គឺជាដីធំធេងមានឆ្នេរ មានភ្នំ មានជ្រលងដងអូរ ទន្លេ បឹងបួរ កោះតូចកោះធំ។ ប្រភពឯកសារ បុរាណៗមិនដែលដៅទីតាំងសុវណ្ណភូមិឱ្យចំច្បាស់ទេ គ្រាន់តែថាជាដែនដីមិនសូវមានមនុស្សរស់នៅ។ នៅសុវណ្ណភូមិ មានរដ្ឋជាច្រើនកកើតឡើង ហើយចេះតែរីកចម្រើនឡើង។

ឈ្មោះ សុវណ្ណភូមិ មានច្រើនរាប់មិនអស់ បើរាប់តាំងពី គម្ពីរនិទ្ទេសជា

[12] នៅក្នុងអត្ថបទរបស់លោក លោកសាស្ត្រាចារ្យសរសេរ សុវណ៌ភូមិ ពោលគឺមិនមានជើងណទេ។ ចំណែកយើងសរសេរតាមអក្ខរាវិរុទ្ធក្នុងអត្ថបទចារឹកនេះ។

ភាសាបាលី ដល់របាក្យត្រជាភាសាស្រីលង្កា ពោលគឺឯកសារសរសេរជាភាសានៅឧបទ្វីបឥណ្ឌាក្តី(មានសំស្ក្រឹត បាលី ប្រាក្រឹត និងតាមីលជាដើម) នៅស្រុកក្រៅពីនោះក្តី (ទីបេ, ចិន, អារ៉ាប់, ពែរ្ស ជាដើម)។

ជារួម ឈ្មោះសុវណ្ណភូមិមាននិយាយក្នុងប្រភពអក្សរសិល្ប៍ពីរធំៗ៖

១- ជំនឿចំណោះតគ្នាអំពីភូមិសាស្ត្រឥណ្ឌាបុរាណ ដែលភាគច្រើនគឺជារឿងនិទានតគ្នាផង រឿងផ្សងព្រេងផង និងមានខ្លះជាកំណត់ហេតុប្រវត្តិសាស្ត្រ។

២- សាវតារឬកាលប្បវត្តិនៃនិកាយថេរវាទ និពន្ធជាភាសាបាលីនៅប្រទេសស្រីលង្កា។ សាវតារទាំងនោះដំណាលថា ក្រោយពីសង្គាយនាទី៣ (ប្រហែលនៅឆ្នាំ២៥០មុនគ.ស. ក្នុងរាជ្យព្រះបាទអសោក) មានព្រះភិក្ខុសង្ឃពីរអង្គព្រះនាមសោនៈនិងឧត្តរៈ បាននិមន្តទៅផ្សាយព្រះធម៌នៅឯដែនដីសុវណ្ណភូមិ។

ឈ្មោះសុវណ្ណភូមិមានលើកនិយាយក្នុងអដ្ឋកថា ជាភាសាបាលីចំណងជើងថានិទ្ទេសនៅសម័យគម្ពីរត្រៃបិតក នៅក្នុងមិលិន្ទបញ្ហា ក្នុងអដ្ឋកថាជាភាសាបាលីសម័យក្រោយគម្ពីរត្រៃបិតក និងក្នុងសាវតារឬកាលប្បវត្តិនៃកោះលង្កា ក្រោមចំណងជើងថា ទីបវង្ស និង មហាវង្ស។

លោកបានលើកបង្ហាញស្ថានីយឬទីតាំងបួនកន្លែង ដែលអាចកំណត់បានថានៅសុវណ្ណភូមិ ដោយយោងលើអត្ថបទចារឹកឬសាស្ត្រាស្លឹករឹតបុរាណៗ។ តំបន់ទាំងបួននោះ គឺលាតសន្ធឹងពីភាគខាងត្បូងនៃប្រទេសភូមាដល់ភាគកណ្តាលប្រទេសថៃនិងកោះសូម៉ាត្រានៃប្រទេស ឥណ្ឌូនេស៊ីហើយមានកាលបរិច្ឆេទរវាងសតវត្សទី១១ដល់ទី១៥នៃគ.ស.។ ស្ថានីយទាំងបួននោះគឺ៖

១- សុវណ្ណភូមិនៅភាគកណ្តាលប្រទេសថៃ។ សិលាចារឹករាមកំហែង (១២៩២ គ.ស.) និងចារឹកវត្តសងកប(១៤០៨គ.ស.)។

២- សុវណ្ណភូមិនៅភាគខាងត្បូងប្រទេសភូមា។ សិលាចារឹកកល្យានីទាំងឡាយ។ នៅឆ្នាំ១៤៩៦គ.ស.មក ស្តេចព្រះនាមធម្មចេតិបញ្ញាឱ្យចារចារឹកកល្យានីជាច្រើន ជាភាសាមននិងភាសាបាលី នៅក្បែរក្រុងប៉េហ្គូ ភាគខាងត្បូងភូមា។ ចារឹកទាំងនេះនៃស្តេចធម្មចេតិ គឺជាចារឹកនិយាយពីសុវណ្ណភូមិ ដោយដើរតាម

គន្លងប្រពៃណី «វង្ស» និពន្ធជាភាសាបាលី។ ផ្ទុយទៅវិញ ចារឹកផ្សេងទៀត (ដែលបង្ហាញនៅក្នុងអត្ថបទនេះ) គឺនិយាយពីសុវណ្ណភូមិទៅតាមលំអាននៃភូមិសាស្ត្រឧបទ្វីបឥណ្ឌានិងភូមិវិទ្យា ក្នុងអក្សរសិល្ប៍ដែលយល់ថាសុវណ្ណភូមិនៅអាស៊ីអាគ្នេយ៍។

៣- សុវណ្ណទ្វីប នៅឧបទ្វីប ម៉ៃម៉ាឡេ។ អដ្ឋកថា «ទុព៌ោជាលោក» នៃព្រះតេជគុណ ធម៌កីតិ (សតវត្សទី១១គ.ស.)។ ព្រះសង្ឃធម៌កីតិបាននិពន្ធអត្ថកថាមួយ អំពីគម្ពីរ «អភិសមយាលង្ការ (អលង្ការនៃការភ្ញាក់ដឹងខ្លួន)»។ ព្រះអង្គបានដាក់ចំណងជើងឱ្យស្នាដៃព្រះអង្គថា «ទុព៌ោជាលោក (ការបំភ្លឺអន្លើពិបាកយល់)»។ ព្រះអង្គនិពន្ធអដ្ឋកថានេះនៅនគរវិជយ នៃសុវណ៌ទ្វីប ក្នុងរាជ្យព្រះបាទទេពស្រី ចូឌាមណិវម៌្មដ៏ជាស្ដេចនគរ កេដាហ (ម៉ាឡាកា) ឥឡូវក្នុងប្រទេសម៉ាឡេស៊ី។

៤- សុវណ៌ភូមិ នៅកោះសូម៉ាត្រា។ ចារឹកអមោឃបាសៈ។ នេះជាចារឹកដែលគេប្រទះឃើញនៅរំបាហាន់ ភាគខាងលិចកោះសូម៉ាត្រា សរសេរជាអក្សរជ្វាបុរាណ(អក្សរកវី)និងជាភាសាម៉ាឡេចាស់។ ចារឹកនេះកត់ត្រាការតម្កល់ព្រះបដិមាព្រះលោកេសូរ ព្រះនាម អារ្យ អមោឃបាស នៅឆ្នាំ១២០៨ នៃមហាសករាជ (១២៨៦គ.ស.)។ ចារឹកនេះ គឺចារលើផ្ទៃនៃព្រះបដិមាកម្ពស់១៦០ស.ម.។ ចារឹកនោះចែងថា ព្រះបដិមានេះគឺយកមកពីភូមិជ្វាទៅកាន់ «ស្វណ្ណភូមិ» ដើម្បីតម្កល់ក្នុងធម៌ាស្រយ មួយទៅតាមព្រះរាជបញ្ជាមហារាជធិរាជស្រីក្រឹតនគរ។ សេចក្ដីក្នុងចារឹកនេះជួយបំពេញព័ត៌មានឱ្យចារឹកលើបន្ទះស្ពាន់ នលន្ទានៃព្រះរាជ ទេពបាលទេព។ ព្រះអង្គបានប្រទាននូវភូមិចំនួនប្រាំទៅតាមសំណូមពរ នៃមហារាជស្រីពាលបុត្រទេព នៃនគរសុវណ៌ទ្វីប ដើម្បីបង្កើនបុណ្យ ព្រមទាំងទានឯទៀតៗ ជាប្រយោជន៍ដល់គណៈសង្ឃនៃទិសទាំងបួន។

លោក ស្ដីល្លិង បានសន្និដ្ឋានថា ទីតាំងទាំងបួននេះ មិនមានអ្វីជាការរកឃើញថ្មីទេ។ ប៉ុន្តែទោះយ៉ាងណា ទីតាំងនេះអាចបញ្ជាក់ថា សុវណ្ណភូមិ គឺជា «កូដវប្បធម៌» មួយ ឬ «កញ្ចប់វប្បធម៌» មួយ ជាទីប៉ងប្រាថ្នានៃនគរនានានៅស្រុកអាស៊ីអាគ្នេយ៍។ ព្រះរាជាក្ដី កវីបណ្ឌិតក្នុងវាំងក្ដី ស្ម័គ្រតាំងខ្លួនថានៅ

ក្នុងសុវណ្ណភូមិ ហើយស្ទើគ្រប់ចូលរួមប្រកាន់អត្តសញ្ញាណតាមគំនិតមួយនេះ។

ស្របតាមគំនិតយោបល់របស់លោក ស្តីល្លិង ចារឹកថ្មីនេះបានជាតឹកតាងមួយទៀតបញ្ជាក់ពីទឹកចិត្តស្រឡាញ់រាប់អានដី «សុវណ្ណភូមិ» ពីសំណាក់ព្រះរាជានិងកវីនិពន្ធនគរខ្មែរ។ ការជ្រើសយកពាក្យ «សុវណ្ណភូមិ» មកប្រើក្នុងល្បះសរសើរយសនៃព្រះបាទឦសានវម៌្មនេះ គឺជាចេតនានៃអ្នកនិពន្ធដែលប្រហែលជាចង់ប្រាប់ថាកាលជំនាន់នោះឈ្មោះ «សុវណ្ណភូមិ» ល្បីល្បាញជាទីស្រមៃនៃស្តេចផងទាំងពួង។ ព្រះរាជាឦសានវម៌្មសោយរាជ្យលើនគរមួយសំបូរភោគទ្រព្យ សក្តិសមនឹងហៅថា «សុវណ្ណភូមិ» មួយនឹងគេដែរ។ ក្នុងចំណោមប្រភពឯកសារទាំងឡាយនៅតំបន់អាស៊ីអាគ្នេយ៍ សិលាចារឹករបស់ព្រះរាជាខ្មែរមួយអង្គនេះ គិតមកដល់ពេលនេះ គឺជាសិលាចារឹកដំបូងគេបំផុតដែលមានពាក្យ «សុវណ្ណភូមិ»។

បើពិនិត្យមើលក្នុងបរិបទសិលាចារឹកនៅប្រទេសកម្ពុជា ពាក្យ «សុវណ្ណភូមិ» មានឃើញប្រើតែក្នុងសិលាចារឹកនេះប៉ុណ្ណោះ។ ដោយឡែក ពាក្យ «សុវណ្ណ» មានន័យថា «មាស» ប្រទះឃើញនៅក្នុងអត្ថបទចារឹកជាង៤០ (មានកាលបរិច្ឆេទរវាងស.វ.ទី៧ដល់ទី១៤) ខ្លះជាសាធារណនាម ខ្លះជាអសាធារណនាម ពោលគឺជាឈ្មោះមនុស្សនិងឈ្មោះទីកន្លែង។ ជាឧទាហរណ៍ ពាក្យ «សុវណ្ណលិង្គ» ដែលមានន័យថា «ព្រះសិវលិង្គមាស» មានឃើញនៅក្នុងអត្ថបទចារឹកមិនតិចជាងប្រាំមួយ រួមមាន៖ K. ៩២៦ (ម.ស. ៥៤៦), K. ៣៤១ (ម.ស. ៥៩៦និង៦២២), K. ១២៧ (ម.ស. ៦០៥), K. ៧០២ (ម.ស. ៦២៥ឬ៦២៦), K. ១០២៩ (ម.ស. ៦៦៥) និង K. ៧៥៤ (ម.ស. ១២៣០) និងឈ្មោះ «ស្រុកសុវណ្ណបុរ» នៅក្នុង K. ៧៧៤ (ម.ស. ៩១១)។ ចំណែកឯពាក្យ «ភូមិ» វិញ មានប្រើក្នុងអត្ថបទចារឹកចំនួនជាង ១៦០ (ស.វ.ទី៧ដល់ទី១៤)។ ស្រដៀងនឹងពាក្យ «សុវណ្ណ» ដែរ វាជាសាធារណនាមមានន័យថា «ដី, ស្រុក» ផង និងជាឈ្មោះទីកន្លែងផង។ សូមជូនឧទាហរណ៍ពីរ៖ ភូមិវ្រៃស្រមោឯម មានន័យថា «ដីព្រៃស្រម៉ឯម» ក្នុងចារឹក K. ១១៥២ (ម.ស. ៨៨៤និង៨៩៩) និង ស្រុកសមភូមិ ក្នុងចារឹក K. ២៩២ (ម.ស. ៩៣៣)។

ត្រលប់មកពាក្យ «សុវណ្ណភូមិ» វិញ យើងអាចចោទសួរថា បើកាលនោះ នគរខ្មែរនិយមរាប់អានគំនិតដែនសុវណ្ណភូមិតាំងពីដើមសតវត្សទី៧ដូចមានចារឹកនេះជាតឹកតាងស្រាប់ ហេតុដូចម្ដេចក៏មានតែចារឹកមួយនេះប្រើពាក្យនេះ ទាំងពាក្យ «សុវណ្ណ» ក៏ដូចជាពាក្យ «ភូមិ» មានប្រើញឹកញាប់ពោល គឺថាហេតុដូចម្ដេចបានជាក្នុងចំណោមចារឹកកម្ពុជាជាង១៤០០ យើងប្រទះឃើញពាក្យ «សុវណ្ណភូមិ» នេះតែមួយ ទាំងពាក្យ «សុវណ្ណ» មានក្នុងចារឹកជាង៤០និងពាក្យ «ភូមិ» ជាង១៦០។ តើអាចទៅរួចទេដែលថា សុវណ្ណភូមិ ជាឈ្មោះជាប់នឹងព្រះពុទ្ធសាសនាប្រហែលដោយសារហេតុនេះទើប ព្រះរាជាដំបូងៗនៃនគរខ្មែរមានព្រះបាទឦសានវម៌្ម ដ៏ជាឦសូរសាសនិកដ៏មុតមាំមិនសូវរំឭកពីឈ្មោះនេះទេ ហើយទម្រាំដល់ពេលព្រះពុទ្ធសាសនា(មហាយាន) បានការលើកតម្កើងជាសាសនារដ្ឋនៅចុងសតវត្សទី១១ ដល់ចុងសតវត្សទី១៣[13] គំនិត «សុវណ្ណភូមិ» បានសាបរលាបទៅហើយ?

## ៧.២- បទនានាក្នុងកំណាព្យសិលាចារឹក

ចារឹកនៅប្រទេសកម្ពុជាជាភាសាសំស្ក្រឹតសឹងតែទាំងអស់ តែងជាបទកំណាព្យ ខុសពីអត្ថបទជាភាសាខ្មែរដែលតែងជាពាក្យរាយឬកម្រងកែវ។ បទកំណាព្យដែលប្រទះឃើញញឹកញាប់ក្នុងសិលាចារឹកគឺ៖ អនុស្ដុភ, ត្រិស្ដុភ (ឧបជាតិ, ឧបេន្ទ្រវជ្រា និងឥន្ទ្រវជ្រា), សាទ៌ូលវិក្រីឌិតា, វសន្តតិលកា, អារ្យា, វំសស្ថា និងមាលិនី។ ក្នុងចំណោមបទទាំងនោះ បទ «អនុស្ដុភ» ជាបទពេញនិយមជាងគេនៅសម័យមុនអង្គរ ក៏ដូចជាសម័យអង្គរ។ ល្បះកំណាព្យជាងពាក់កណ្ដាលនៃសិលាចារឹកទាំងអស់នៅប្រទេសកម្ពុជា តែងជាបទ «អនុស្ដុភ» នេះ។ ឧទាហរណ៍៖ ចារឹកប្រែរូប(ឆ្នាំ៨៦១មហាសករាជ) ដែលជាចារឹកភាសាសំស្ក្រឹតវែងជាងគេនៅប្រទេសកម្ពុជា តែងជាបទ «អនុស្ដុភ» ចំនួន

---

[13] លោកសាស្ត្រាចារ្យ ភីឋឺ ស្ហែរ៉ក (Peter Sharrock ២០១៨, ទំព័រ ១១២) បានគូសបញ្ជាក់ថា «ចាប់ពីឆ្នាំគ.ស.១០៨០ ដល់គ.ស.១២៧០ នៅពេលចក្រភពខ្មែរមានអំណាចកប់ពពក មានព្រះរាជា៥អង្គ ក្នុងចំណោម៦អង្គ ជាពុទ្ធសាសនិក រីឯព្រះបាទសូយ៌្យវម៌្មវិញជាវិស្ណុសាសនិក (អ្នកគោរពបូជាព្រះនារាយណ៍)។» ជាភាសាអង់គ្លេស ៖ “[…] from 1080 to 1270 CE, when the empire achieved its apogee, five out of six kings – Jayavarman VI, Dharanīndra, Tribhuvanāditya, Jayavarman VII and Indravarman II – were Buddhists and Sūryavarman was Vaiṣṇava.”

១៤៩ល្បះ ក្នុងចំណោម២៩៨ល្បះ។ បទ «អនុស្តុភ» នេះ គេយកប្រើតែង រៀបរាប់ពីប្រធានបទផ្សេងៗរួមមាន៖ បទថ្វាយបង្គំព្រះ, ពង្សាវតារ, កាលបរិច្ឆេទ, ការដាក់បណ្តាសា, ការជូនពរ និងការរៀបរាប់ពីទ្រព្យធនតាមប្រាសាទ ឬទីសក្ការៈនានា។

ប៉ុន្តែមានសិលាចារឹកខ្លះចៀសមិនមានបទ «អនុស្តុភ» ទេ។ សូមលើកយកឧទាហរណ៍ពីរ៖ ១- សិលាចារឹកទួលព្រះធាតុ(៦៧៣មហាសករាជ)តែងជាបទ «អារ្យា» ចំនួន១១ល្បះ, ២- ចារឹកបន្ទាយស្រី(លេខ៥៦៨ សតវត្សទី១៣) មាន២៤ល្បះតែងជាបទវសន្តតិលកា, ឥន្ទ្រវជ្រា, ឧបេន្ទ្រវជ្រា និងសាទ្ទូលវិក្រីឌិតា។

ចំណែកចារឹកសុវណ្ណភូមិនេះ អាចរាប់ថាជាចារឹកដំបូងគេបំផុតគេ ដែលមិនមានបទ «អនុស្តុភ»។ កំណាព្យនេះមាន១១ល្បះ តែងជាបទចំនួនបីគឺ៖ ឧបជាតិ, ឥន្ទ្រវជ្រា និងឧបេន្ទ្រវជ្រា។ បទទាំងបីនេះស្ថិតក្រោមបទធំតែមួយឈ្មោះថា «ត្រិស្តុភ»។ បើយោងតាមការពិនិត្យចារឹកចំនួន៣០នៅសម័យមុនអង្គរ មានល្បះប្រមាណ១០ភាគរយ តែងជាបទត្រិស្តុភ។ ដើម្បីឱ្យដឹងពីប្រជាប្រិយភាពនៃបទត្រិស្តុភនេះនៅសម័យមុនអង្គរនិងសម័យអង្គរ យើងត្រូវស្វែងមើលអត្ថបទឱ្យបានច្រើន។

## **៧.៣- កាលបរិច្ឆេទ**

ការបង្ហាញពីលក្ខណៈតារាសាស្ត្រមានបញ្ហាខ្លះៗ ជាពិសេសទាក់ទងនឹងពាក្យ «វីនា» នៅបន្ទាត់ទី២១។ ពាក្យនេះ គួរកែជា «វីណា» ដែលមានន័យថា «ពិណ» វិញ។ លោក ប៊ីល ម៉ាក ស្នើសុំកែ ពាក្យវីណានេះ ទៅជា មីនា "ត្រី"។ ប៉ុន្តែលោក ខាលហាញ ហ្គោលហ្សិយោ យល់ថាពាក្យ វីណានេះសំដៅដល់ ពាក្យ កន្យា/កញ្ញា "ក្មេងស្រីជំទើរ" ពោលគឺ "ក្មេងស្រីជំទើរកាន់ពិណ"។ ក្នុងវចនានុក្រមសំស្ក្រឹតរបស់លោក ម៉ូនៀ វិល្លៀម ពាក្យ «វីណា» ក៏អាចមានន័យថា «សណ្ឋាននៃផ្កាយទាំងអស់ ពេលកព គ្រោះទាំង អស់ ស្ថិតនៅក្នុងល្វែងចំនួន៧»។ ប៉ុន្តែអត្ថន័យនេះនៅតែចោទជាបញ្ហា ព្រោះនៅក្នុងបរិបទល្បះនេះ យើងរំពឹងពាក្យមួយប្រាប់ឈ្មោះល្វែង ដូចជា មីនា ជាដើម។

# ឧបសម្ព័ន្ធ
# Appendix
## Edition and Annoted Translation of K. 1419

**By**

**Chhom Kunthea, Researcher, Apsara Authority**[14]

The inscription was found at Vat Kiri Sdech Kong (alias Vat Boeung) by local villagers about 20 years ago. The Vat or pagoda is situated in Trapeang Khtum village, Svay Cacep commune, Boset district, Kompong Speu province. Informed by his student, Ms. Vang Puthy, Dr. Vong Sotheara, specialized in epigraphy and South East Asian history, made an estampage of the inscription on December 22, 2017. The inscription in question is a stela made of schist. It narrows towards the base and at its summit is shaped like a down-turned curly brace. It measures 135 cm in height and 7.5 cm in depth while it is 54.5 cm wide at the top and 51.5 cm at the bottom.

The text is entirely in Sanskrit. It consists of twenty lines forming eleven stanzas. Arranged in two columns, the Sanskrit verses are carved in a calligraphic manner and in three prosodic meters: Upajāti of Triṣṭubh (st. I, II, IV, VI, VIII, IX, XI), Indravajrā (st. III, V, VII) and Upendravajrā (st. X). The first three stanzas contain an invocation of the gods Śiva, Śiva-Viṣṇu and Viṣṇu. Stanza IV praises king Īśānavarmman as king of kings. Stanzas V–VIII present the protagonist, a king's servant (*bhṛtya*) of the king called Vrau Etta, and record his installation of several divine images and donations of paddy-fields and cattle. An imprecation is pronounced in stanza IX. The last two stanzas specify that the installation of an image of Hara-Kṛṣṇa (Śiva-Viṣṇu) by the founder (Vrau Etta) happened on the first

[14] The author would like to thank Professors Dominic Goodall, Arlo Griffiths, Hans Henrick Hock, Dániel Balogh, McComas Taylor, Karl-Heinz Golzio and Bill Mak for sharing their translations and their views on several verses of the inscription. The remaining mistakes and shortcomings are the author's responsibility.

night of the lunar month of Caitra (March-April) of year 555 in the *Śaka* era, i.e. in 633 CE.

As soon as its existence was made known in December 2017, the inscription caught the attention of the public in Cambodia and beyond. The focus of interest is the Sanskrit term *suvarṇa-bhūmi* in stanza IV, which is a compound of two words: suvarṇa 'gold' and *bhūmi* 'earth'. The term is used in the praise of king Īśānavarmman, who is described as ruling across the surface of the golden earth (*suvarṇabhūmi*). Many territories of Southeast Asia have claimed to be the 'Golden land'. But this, as far as we are aware, is the only attestation of the expression ever found in Southeast Asian epigraphy.

## Edition and Translation

I. [Upajāti of Triṣṭubh]

**(1)** jayaty adhīśas sura-mauli-kūṭa-cūḍā-maṇīn visphurad-unmayūkhān·

**(2)** vijitya tan-mūrddhasu yasya pāda-nakha-prabhāviṣkr̥ta-candra-kāntiḥ (||)

Victorious is the Supreme Lord [Śiva], the radiance of whose toe-nails (*pādanakhaprabhā*) — vanquished the quiveringly radiant crest-jewels of the multitude of diadems of the gods —, made moonlight to appear (*āviṣkr̥tacandrakāntiḥ*) on their heads (*tanmūrddhasu*).[15]

II. [Upajāti of Triṣṭubh]

**(3)** śrīśāna-viṣṇū jayatas sureśau yayoś śarīrārddha-samāgamena

**(4)** Āvir-vvabhūvāmara-māṇaveṣu vibhutvam ekatvam anekatā ca ||

[15] In Angkorian epigraphs, the image of vassal kings bowing down at feet of the king and the light of the latter's toenails mixing with the light from their crest-jewels is widely used.

May the two Lords of the gods, (namely) Śrī Īśāna and [Śrī] Viṣṇu, be victorious! By the uniting of their body-halves, immanence, oneness and plurality are made manifest among gods and mortals.

III. [Indravajrā]

**(5)** vaktreṇa dhīś śrīr urasā ca padbhyāṁ (bh)ūḫ[16] pālitāsmat-patinātibhāgyāt·

**(6)** kṣiptā hi dūraṁ yad ahan tv adhanyā yaṁ kīrttir ud-diśya vaded itīva ||

About him (*yam uddiśya*), Fame seemed to say (*vaded itīva*): "With his mouth, this Lord of ours protects Wisdom; with his chest Śrī; with his feet Earth, because of his great good fortune; but (*tu*) I am unlucky (*adhanyā*), because (*yad*) I have evidently (*hi*) been cast (*kṣiptā*) far aside (*dūram*)".[17]

IV. [Upajāti of Triṣṭubh]

**(7)** samudraparyyantasuvarṇṇabhūmipṛṣthaikarājendraparākra maśrīḥ

**(8)** samastasāmantaśirodhṛtājñaś śrīśānavarmmā jayati kṣitīśaḥ[18] ||

---

[16] *(bh)ūḫ*: the shape of *bhū* here is different from what we see in lines 4 and 15, which can be explained as due to limitation of space in the present context; anyhow, the consonant part seems to have been engraved with hesitation, leading to its imperfect realization.

[17] For this construction with *yad*, compare, e.g., *Raghuvaṁśa* 3.25: *yad āha dhātryā prathamoditaṁ vaco yayau cāṅgulim | abhūc ca namraḥ praṇipātaśikṣayā pitur mudaṁ tena tatāna so 'rbhakaḥ*, "Because he spoke the words his nurse had spoken first, because he walked hanging on her finger, and because he bent when he was taught to bow, the child brought joy to his father."

[18] The expression *śrīśānavarmmā jayati kṣitīśaḥ* is also found in the second stanza of K. 80 (7th century CE, Vat Prei Veng/ Svay Chno, Dangko District, Phnom Penh). In that stanza, King Īśānavarman is described as a glorious king of three kings (*bhūpatrayasyoruyaśo vidhātā*), a possessor of three cities (*bhoktā nagaratrayasya*) and comparable to Lord Hara (Śiva). We also learn from the last two stanzas, st. III and IV, that Vidyādeva established a hermitage (*āśrama*) and offered servants, cows and plantations of areca and coconut. This inscription seems to be composed in the same spirit as the one we edit here. A systematic study of the inscriptions under the reign of King Īśānavarman like K. 80 is a desideratum.

Victorious is the lord of the earth Śrī Īśānavarman, whose commands were carried on the head by all the vassal kings,

whose glory (°*śrīḥ*) and heroism (°*parākrama*°) are those of Indra who is the unique sovereign (°*ekarāja*°) on the surface (°*pṛṣṭha*°) of the golden earth (°*suvarṇabhūmi*°), up to the oceans (*samudraparyanta*°).

or

whose glory (°*śrīḥ*) and heroism (°*parākrama*°) are those of a king of kings who is alone on the surface (°*pṛṣṭha*°) of the golden earth (°*suvarṇabhūmi*°), up to the oceans (*samudraparyanta*°).

or

whose glory (°*śrīḥ*) and heroism (°*parākrama*°) are those of a king of kings who is alone on the surface (°*pṛṣṭha*°) of the earth, which is of beautiful color (°*suvarṇa*°), up to the oceans (*samudraparyanta*°).

or

whose glory (°*śrīḥ*) and heroism (°*parākrama*°) are those of a king of kings who is alone on the surface (°*pṛṣṭha*°) of the land [which is named] Suvarṇa up to the oceans (samudraparyanta°).[19]

V. [Indravajrā]

**(9)** tasyāpi bhṛtyas samadhatta saṁjñāṁ vrau Etta Ity ātmagurupradiṣṭāṁ

**(10)** tatpūrvvaje sthāpitavaty anādiṁ śrīpuṣkareśaṁ prathamaṁ

---

[19] In Khmer version, we propose other two possible interpretations as follows:

whose glory (°*śrīḥ*) and heroism (°*parākrama*°) are those of a king of kings who is alone on the surface (°*pṛṣṭha*°) of [the land called] Suvarṇabhūmi up to the oceans (*samudraparyanta*°).

or

whose glory (°*śrīḥ*) and heroism (°*parākrama*°) are those of a king of kings who is alone on the surface (°*pṛṣṭha*°) of the earth [which is in the] Suvarṇabhūmi up to the oceans (*samudraparyanta*°).

For a historiography of the term Suvarṇabhūmi, see our comment in the Khmer version of this article. In this volume, Vong Sotheara also discusses this term at length from a historical point of view.

surāṇāṁ ||

Now (*api*) a servant of his received (*samadhatta*) the name Vrau Etta[20], which was dictated by his own spiritual master, after his (the servant's) elder brother had installed Śrī Puṣkareśa[21], the one without beginning and the first among the gods.

VI. [Upajāti of Triṣṭubh]

**(11)** guros svabhaktyā bhaginīṁ murāreḥ śrīśarvvagovindam atiṣṭhipat saḥ

**(12)** svayambhudevībhavakeśavānāṁ tenāpi saṁsthāpita Ekabhogaḥ (||)

Out of personal devotion (*svabhaktyā*) toward his spiritual master, he installed the sister (*bhaginīm*) of Murāri [as well as] Śrī Śarva and [Śrī] Govinda. He also (*api*) established single enjoyment [of offerings] (*ekabhogaḥ*) among (these three deities, namely) Svayambhudevī,[22] Bhava and Keśava.

VII. [Indravajrā]

**(13)** teṣāṁ surāṇām iha bhr̥tyasaṁkhyā saṁpiṇḍitā syāt triśatī gavāñ ca

**(14)** sā triṅśatī kṣetrakamāhiṣāṇāṁ pratyekam ārāma Iti trayāṇāṁ ||

---

[20] Vrau Etta may be a name with a beneficent connotation. For a discussion on this name, see Michel Antelme's article in Khmer in the next issue of Kambuja Suriya.

[21] According to D. Goodall (personal communication, December 2019), this seems to be the name of a Viṣṇu with a Śaiva-sounding element, see the remaks of A. Griffiths (2005) on the Vaiṣṇava theonym Tribhuvaneśvara in K. 1214. The installation of the god Puṣkareśa is also mentioned in two contemporary inscriptions, K. 121 (638 *śaka*, Preah Theat Kvan Pir, Kratie province) and K. 765 (601 *śaka*, Prasat Neang Khmau, Takeo province).

[22] D. Goodall (personal communication, December 2019) thinks that Svayambhudevī is the name of the goddess, who is presented as the sister of Murāri, perhaps because she is thought of as Subhadrā (and the last stanza might be taken to suggest that the Viṣṇu is a Kr̥ṣṇa here), but perhaps also because Viṣṇu gives Pārvatī to Śiva when Śiva marries her (as represented, e.g., in South Indian Kalyāṇasundaramūrtis), and the goddess, both in Cambodia and in Tamil Nadu, bears *cakra* and *śaṅkha* (even when she appears in Śaiva contexts).

‘For these [three] gods [installed] here, the number of servants, [once] added up together (*saṁpiṇḍitā*) shall be three hundred, and [the same too] of cows; that [number] for the fields and buffaloes is thirty; for each of the three individually (*pratyekam*) there is a garden.’

VIII. [Upajāti of Triṣṭubh]

**(15)** Etāni gobhūdhanapūrvvakāṇi sarvvāṇi dharmmārttham upārjjitāni

**(16)** pade kulānāṁ svakulaikadīpo vrau Ettanāmādita devatābhyaḥ ||

A unique lamp in his own lineage, [the man] named Vrau Etta gave all these things, beginning with cows, land and wealth, to the gods in [this] place belonging to good families (*pade kulānām*), offered up (*upārjitāni*) for the sake of the meritorious foundation (*dharmārtham*).

IX. [Upajāti of Triṣṭubh]

**(17)** yajvā trayāṇām iha devatānāṁ datvā dhana(ṁ) yo harati sma lobhāt·

**(18)** saha prasūtyā niraye nimajjed āsaṁplavāt sthāvarajaṅgamānāṁ (||)

After the donor (*yajvan*) has given wealth to the three gods here, whoever, out of greed, will have (*sma*)[23] taken away (*harati*) [this wealth] will fall into hell along with his descendants [and remain there] until the destruction of movable and immovable beings.

[23] In Cambodian inscriptions composed in Sanskrit, the particle *sma* is attested a dozen times in the context of praise of kings and elites. However, in the context of boon and curse, the use of the particle in this formula of imprecation appears to be the first attestation. M. R. Kale (2002: 236) explains that *sma* is generally used as an expletive. Used with a form of the present tense of the verb, it gives it the sense of the past tense. In the context of the inscription, the particle *sma* is translated with a future perfect because it indicates that the act of stealing will be in the past with respect to the punishment which the miscreant will receive.

X–XI. [Upendravajrā]

**(19)** samā śakendrasya śareṣuvāṇair vvinirggatā caitrasitādirātriḥ

**(20)** yadāśvīnīśītakaro[24] nuyātrī tulodayo maithunabhāgayukta(ḥ ||)

**(21)** mīnājavīnājhaṣamārggakumbhacāpakramasthāś śubhalagnadās te

**(22)** [sū]ryyādayaś śrīharakr̥ṣṇamūrttim atiṣṭhipat tāṁ vidhineha yajvā (||)

When the year of the Śaka king had emerged from the (5) arrows (*śara*), the (5) arrows and the (5) arrows, [when it was] the first night of the waxing moon of Caitra, [when] the Moon was in Aśvinī, the ascendant partly linked with Gemini (*maithuna*) in Tula, [while] the Sun and other planets (which make a moment auspicious, i.e. Moon, Mars, Mercury, Jupiter, Venus and Saturn) were (respectively) in Pisces (*mīna*), Aries (*aja*), Vīnā (?),[25] Pisces (*jhaṣa*), Capricorn (*mārga*), Aquarius (*kumbha*) and Sagittarius (*cāpa*) — [that is when] the donor properly installed the images of Śrī, Hara and Kr̥ṣṇa here.

[24] For the meter and for the sense we need to read *śvi* here.

[25] It is most probable that *vīnā* is to be corrected into *vīṇā* which generally means 'Indian lute' but in astrology, according to M. Monier-Williams (2005: 1005) it can refer to a particular configuration of the stars (when all planets are situated in seven houses). Nevertheless, the meaning does not seem to fit in this context, where a name of a zodiac sign is expected.

# ឯកសារពិគ្រោះ


Coedes, George 1937-1966 *Inscriptions du Cambodge*, 8 vol., Hanoi-Paris, EFEO.

Griffiths, Arlo, en collaboration avec J.C. EADE & Gerdi Gerschheimer 2005 "La stèle d'installation de Śrī Tribhuvaneśvara : une nouvelle inscription préangkorienne du musée national de Phnom Penh (K. 1214)", *Journal Asiatique* 293/1, p. 11–43.

Jenner, Philip N.

2009a *A Dictionary of Pre-Angkorian Khmer*, Canberra, the Australian National University.

2009b *A Dictionary of Angkorian Khmer*, Canberra, the Australian National University.

Kale, M. R. 1982 *A Higher Sanskrit Grammar*, Delhi, Motilal Banarsidass Publishers (eighth edition).

Monier-Williams, Monier 2005 *A Sanskrit-English Dictionary*, (Repr.) Delhi, Motilal Banarsidass, (1st edition: 1899, Oxford University Press).

POU, Saveros 2004 *Dictionnaire Vieux-Khmer – Français – Anglais. An Old Khmer – French – English Dictionary*. Paris, L'Harmattan, 2e édition augmentée (1re édition : Paris, Cedoreck, 1992).

Revire, Nicolas 2018 *"Facts and Fiction: The Myth of Suvaṇṇabhūmi through the Thai and Burmese Looking Glass"*, Trans-Regional and –National Studies of Southeast Asia 6/2, pp. 167-205.

Sharrock, Peter 2018 "Cham-Khmer interactions 1113-1220 CE", *Vibrating in stone: Masterpieces of the Da Nang Museum of Cham Sculpture*, (ed.) Tran Ky Phuong, Vo Van Thang & Peter D. Sharrock, River Books, pp. 111-119.

Skilling, Peter 2019 *"Many Lands of Gold", The Golden Land Suvarnabhumi: The New Finding for Suvarnabhumi Terra Incognita*, (ed.) Bunchar Pongpanich and Somchet Thinapong, Geo-Informatics and Space Technology Development Agency (Public Organization), pp. 191-217.